# របាយការណ៍សង្ខេបនៃកិច្ចសន្ទនា

# រវាងក្រសួង-ស្ថាប័នជាតិនៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងបណ្តាញអង្គការសង្គមស៊ីវិលធ្វើការលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ អំពី

## «សេចក្តីស្នើក្នុងការបង្កើតក្រុមការងារចម្រុះ ដើម្បីសិក្សានិងពិភាក្សាលើទិដ្ឋភាពផ្លូវច្បាប់ទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នានៅប្រទេសកម្ពុជា»

### នាឱកាសអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០២៣

### សណ្ឋាគារហ៊ីម៉ាវារី ថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០២៣

រៀបចំដោយ៖ បណ្តាញអង្គការសង្គមស៊ីវិលធ្វើការលើសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ (SOGIESC) និងសិទ្ធិសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ (SRHR) នៅប្រទេសកម្ពុជា

# គោលបំណង

នាឱកាសអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០២៣ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងបណ្តាញអង្គការសង្គមស៊ីវិលបានសហការរៀបចំកិច្ចសន្ទនា ដើម្បីបន្តពិភាក្សាជាមួយក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាអំពីជំហានជាក់លាក់ធ្វើឱ្យមានវឌ្ឍនភាពនៃការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ស្របតាមអនុសាសន៍នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) ជុំទី៣ ដែលបានទទួល។

កិច្ចសន្ទនានៅថ្ងៃចន្ទ ទី៤ ខែធ្នូ ឆ្នាំ២០២៣ បានពិភាក្សាផ្តោតយ៉ាងជាក់លាក់លើសេចក្តីស្នើរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងបណ្តាញសង្គមស៊ីវិលជូនចំពោះក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រសួងមហាផ្ទៃ ដើម្បីពិចារណាបង្កើតក្រុមការងារចម្រុះ ឬ យន្តការប្រហាក់ប្រហែល ទទួលបន្ទុកពិភាក្សា សិក្សា និងពិនិត្យក្របខណ្ឌផ្នែកផ្លូវច្បាប់ អនុញ្ញាឱ្យមានសមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នានៅប្រទេសកម្ពុជា។




អ្នកចូលរួមនៅក្នុងកិច្ចសន្ទនានៅក្នុងឱកាសអបអរទិវាសិទ្ធមនុស្សអន្តរជាតិ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣
ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កែវ រ៉េមី ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# តំណាងថ្នាក់ជាតិនៃរាជរដ្ឋាភិបាលកម្ពុជាដែលរមែងគាំទ្រសិទ្ធិសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា បន្តអំពាវនាវកុំឱ្យមានការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា







នៅក្នុងសន្ទរកថាស្វាគមន៍ និងបើកកម្មវធី **ឯកឧត្តម កែវ រ៉េមី** បានទទួលស្គាល់នូវសមត្ថភាព និងទេពកោលស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងចូលរួមចំណែកអភិវឌ្ឍសង្គមកម្ពុជា តាមរយៈចំណេះដឹង និងបទពិសោធន៍របស់ខ្លួន។ ឯកឧត្តមបានគូសបញ្ជាក់ថា អ្នកស្រឡាញ់ភេទដូចគ្នាគឺជាធម្មជាតិ មិនមែនជាជំងឺទេ។ សេចក្តីស្រឡាញ់ និងតម្រូវការរបស់អ្នកស្រឡាញ់ភេទដូចគ្នាគឺជាកត្តាជំរុញទឹកចិត្តឯកឧត្តមចូលរួមយ៉ាងសកម្មជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ហើយមិនដែលទុកឱ្យអ្នកស្រឡាញ់ភេទដូចគ្នាមានអារម្មណ៍ឯកាឡើយ។

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# គណៈវាគ្មិនជាតំណាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា




ឯកឧត្តមឧត្តមសេនីយ៍ឯក ឌឿន ចាន់ដារ៉ា
អនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ




លោកជំទាវ ទេស រ័ត្ននីរ៉ា
សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# គណៈវាគ្មិនជាតំណាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា បណ្តាញសង្គមស៊ីវិល និងឪពុកម្តាយ




លោកស្រី ឈុន មុន្នីវិច្ឆរ៉ា




លោក វឿន ដារីន




លោក គុយ ធីតា




លោកស្រី លី ពិសី




លោក លេស តិះ




លោកស្រី ជ័យ សុខដុម




លោកស្រី ពៅ ដាលីន




លោក ធី សុខុម

អ្នកសម្របសម្រួល៖ លោកស្រី សួង សុខសោភា



# សេចក្តីសង្ខេបនៃការឆ្លើយតបពីគណៈវាគ្មិនតំណាងរាជរដ្ឋាភិបាលលើបរិបទផ្នែកផ្លូវច្បាប់ និងសង្គមកម្ពុជា

នៅអំឡុងពេលនៃកិច្ចសន្ទនា គណៈវាគ្មិនអញ្ជើញមកពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលបានលើកឡើងថាៈ

- ❖ ប្រទេសកម្ពុជាមិនទាន់ទទួលស្គាល់អាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នានៅឡើយទេ ដោយមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណី ហើយវិសោធនកម្មច្បាប់ទាមទារពេលវេលា និងភាពអត់ធ្មត់។

- ❖ អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាគួរតែបន្តធ្វើជាមនុស្សដែលមានគំរូល្អ ដើម្បីជំរុញទឹកចិត្តរាជរដ្ឋាភិបាលឱ្យចាប់អារម្មណ៍ ទទួលស្គាល់ និងមានលទ្ធភាពក្នុងការពិនិត្យ និងវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអាចអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។

- ❖ អង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជាបន្តផ្សព្វផ្សាយចំណេះដឹងទៅដល់សាធារណជនឱ្យកាន់តែទូលំទូលាយ ក្នុងបញ្ឈប់ការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា។

ខ្ញុំទទួលយក

## សេចក្តីសង្ខេបនៃការឆ្លើយតបពីគណៈវាគ្មិនតំណាងរាជរដ្ឋាភិបាលលើបរិបទផ្នែកផ្លូវច្បាប់ និងសង្គមកម្ពុជា លើជម្រើសនៃក្រុមការងារ (១)

- ឆ្លើយតបនឹងសំណើរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងបណ្តាញអង្គការសង្គមស៊ីវិលធ្វើការលើសិទ្ធិ SOGIESCនិង SRHR ក្នុងការបង្កើតក្រុមការងារចម្រុះដែលមានសមាសភាពក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ព្រមទាំងធ្វើជាស្ថាប័នសម្របសម្រួល គណៈវាគ្មិននៃតំណាងរាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា៖
  - មិនមានទម្រង់ក្រុមការងារចម្រុះដែលមានសមាសភាពក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដូចសំណើនោះទេ។ កន្លងមកធ្លាប់មានតែក្រុមការងារអន្តរក្រសួង។
  - ស្ថាប័នសម្របសម្រួលក្រុមការងារចម្រុះនេះតម្រូវឱ្យមានសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា។
  - លទ្ធភាពដែលអាចធ្វើបាន មានភាពប្រសើរ និងលឿនគឺជម្រើសគំរូដែលអង្គការសង្គមស៊ីវិលបង្កើតក្រុមការងាររបស់ខ្លួន ហើយស្នើសុំក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីចូលរួមជួបប្រជុំពិភាក្សាលើកម្មវត្ថុអាទិភាព។

# សេចក្តីសង្ខេបនៃការឆ្លើយតបពីគណៈរាជរដ្ឋាភិបាលលើបរិបទផ្នែកផ្លូវច្បាប់ និងសង្គមកម្ពុជា លើជម្រើសនៃក្រុមការងារ (២)

កិច្ចសន្ទនាបានសំយោគនូវជម្រើស ៣ សម្រាប់ជំហានបន្ទាប់ដូចខាងក្រោម៖

១.អង្គការសង្គមស៊ីវិលបង្កើតក្រុមការងាររបស់ខ្លួន ឧទាហរណ៍ក្នុងចំណោមក្រុមការងារស្ម័គ្រចិត្ត និងស្ថាប័នចំនួន ១៤ ដែលធ្វើការលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិ SOGIESC សិទ្ធិ SRHR និងអន្តរប្រសព្វនៃសិទ្ធិស្ត្រី។

⟺

២. ធ្វើការតាមរយៈក្រុមការងារដែលមានស្រាប់ និង/ឬបង្កើតថ្មី របស់ក្រសួង-ស្ថាប័នសាមីនៃរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកលើវិស័យ ឬ ផ្នែកជាក់លាក់ (**ក្រុមការងាររបស់ក្រសួង ឬស្ថាប័នសាមី**)។ *ជម្រើសនេះត្រូវបានស្វាគមន៍ដោយគណៈវាគ្មិននៃក្រសួងមហាផ្ទៃ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីបន្តកិច្ចសន្ទនានៅពេលក្រោយទៀត។*

⟺

៣. ធ្វើការតាមរយៈក្រុមការងារអន្តរក្រសួងដែលមានស្រាប់ ឬបង្កើតថ្មីទទួលបន្ទុក វិស័យ ឬផ្នែកជាក់លាក់ ឬ ពាក់ព័ន្ធ ដែលអាចមានសមាសភាពក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។

## ជំហានបន្ទាប់

ក្រុមការងារបណ្តាញសង្គមស៊ីវិលដាក់លិខិតអញ្ជើញ ឬលិខិតស្នើសុំជួបប្រជុំជាមួយតំណាងជំនាញបច្ចេកទេសដោយមានការចាត់តាំង ដោយបញ្ជាក់នូវកម្មវត្ថុច្បាស់លាស់ ដើម្បីពិភាក្សាលើផែនការសកម្មភាពជាក់លាក់លើការសិក្សា និងពិនិត្យក្របខណ្ឌផ្នែកផ្លូវច្បាប់របស់កម្ពុជាដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា។

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# សារៈសំខាន់ និងសេចក្តីសង្ឃឹមចំពោះអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា

**លោកស្រី ឈុន មុន្នីវិច្ឆរ៉ា សមាជិកសកម្មរបស់រ៉ក់៖**

*«សព្វថ្ងៃខ្ញុំជាគ្រូបង្រៀន រយៈពេលជាង ១០ឆ្នាំហើយ នៅអនុវិទ្យាល័យមួយ។ ខ្ញុំមានដៃគូរស់នៅជាមួយគ្នាប្រហែល៥ឆ្នាំ ក្តីស្រឡាញ់របស់យើងមិនមែនជោរតាមគ្នា តែជាក្តីស្រឡាញ់ដោយចិត្តនិងចិត្ត ដែលមានការយោគយល់ និងចេះអធ្យាស្រ័យឱ្យគ្នា។ យើងចង់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់ ព្រោះពេលពួកយើងមានកូន ដើម្បីបញ្ជាក់ថា យើងជាឪពុកម្តាយរបស់កូនយើង។»*



# សារៈសំខាន់ និងសេចក្តីសង្ឃឹមចំពោះអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា

**លោក ធី សុខុម សមាជិករ៉ក់៖**

*«បច្ចុប្បន្នខ្ញុំមានអាយុ៧០ឆ្នាំហើយ ខ្ញុំមិនចង់ឱ្យអ្នកជំនាន់ក្រោយឆ្លងកាត់ការលំបាកដូចខ្ញុំនោះទេ ។ ខ្ញុំរស់នៅក្នុងស្រុកភូមិ គេមិនឱ្យតម្លៃ មិនមានអ្នករាប់រក ដោយសារតែខ្ញុំក្រ និងជាអ្នកស្រឡាញ់ភេទដូចគ្នា។ ខ្ញុំប្រាថ្នាជាមនុស្សប្រព្រឹត្តអំពើល្អ ខិតខំ តស៊ូទៅមុខបន្តទៀត និងសូមឱ្យរដ្ឋាភិបាលជួយគិតគូជនចាស់ជរាគ្មានទីពឹងដូចខ្ញុំដើម្បីទទួលបានប័ណ្ណក្រីក្រទុកសម្រាប់ព្យាបាលជំងឺ។»*




ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# លោកឪពុកដែលទទួលយក និងគាំទ្រកូនជាអ្នកស្រឡាញ់ភេទដូចគ្នា

**លោក លិះ តេស ឪពុករបស់កូនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា៖**

*«ប៉ាស្រឡាញ់កូន ប៉ាទៅតាមកូនជានិច្ច មិនថាកូនទៅទីណា។ ទឹកចិត្តរបស់ប៉ា គឺស្រឡាញ់កូន មិនខ្វល់ថាកូនមាននិន្នាការភេទអ្វី កូនជ្រើសរើសស្រឡាញ់នរណា ឬកូនជ្រើសរើសការងារអ្វី ស្រេចតែកូន ឱ្យតែកូនស្រឡាញ់ ដូចដែលប៉ាជ្រើសរើសស្រឡាញ់កូនដូចគ្នា។»*















ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

## អំពីរោងជ័យមង្គល "គ្រួសារកក់ក្ដៅ"
## ថ្ងៃចន្ទ ទី៤ ខែធ្នូ ឆ្នាំ២០២៣

ចំណងអាពាហ៍ពិពាហ៍ដែលវេញត្របាញ់ចូលគ្នារវាងបេះដូងនឹងបេះដូងរបស់មនុស្សពេញវ័យពីរនាក់ ក្រោមកម្រងផ្កាស្លាជាសារជូនពរជ័យ ព្រមទាំងជាការសណ្ដោសប្រណីពីឪពុកម្ដាយ ចាស់ទុំ និងញាតិសន្តានចំពោះក្ដីស្រឡាញ់នេះគឺជាសេចក្ដីប្រាថ្នារបស់មនុស្សភាគច្រើន។

កិច្ចសន្យាស្នេហាជាលាយលក្ខអក្សរដ៏ឱឡារិក គឺជាសក្ខីភាពតាមក្បួនតម្រាជាអាផ្សាទទួលស្គាល់ចំណងអាពាហ៍ពិពាហ៍ស្របតាមផ្លូវច្បាប់ និងជាគ្រឹះសម្រាប់កសាងទំនុកចិត្តរវាងគ្នា ព្រមទាំងការពារនិងពង្រឹងក្រុមគ្រួសារឱ្យកាន់តែរឹងមាំ។

រោងជ័យមង្គល "គ្រួសារកក់ក្ដៅ" បង្ហាញពីសេចក្ដីប្រាថ្នារបស់គូស្រករភេទដូចគ្នាដែលមានសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធនិងជ្រាលជ្រៅចំពោះគូជីវិតរបស់ខ្លួន ដោយសង្ឃឹមថានឹងអាចទទួលបានទាំងចំណងផ្កាស្លា និងកិច្ចសន្យាអាពាហ៍ពិពាហ៍ស្របទៅតាមគុណតម្លៃវប្បធម៌ប្រពៃណី និងស្របតាមបទបញ្ញត្តិរបស់ព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំទទួលយក

## THE HALL OF "WARM FAMILY"
## Monday, 4th December 2023

The wedding knot tied together by the hearts of two adults that is blessed with betelnut flowers and is a compassion of parents, the elderly, and extended family toward this love is the dream that most people wish for.

The written love agreement is an evidence based on with legal recognition of marriage as is a foundation to build trust, protect and strengthen family to be stronger.

The Hall of "Warm Family" reveals the dreams of LGBT+ couples who their love is extremely pure and deep down inside their hearts with a hope to receive a betelnut flower blessing and marriage certificate respecting cultural and traditional values, and laws of the Kingdom of Cambodia.

ខ្ញុំទទួលយក











ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RUCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# អាផ្ទាធរម្មូលដ្ឋានស្តាប់ពីបញ្ហាប្រឈម និងតម្រូវការរបស់គូស្រករគ្រួសារ និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា




**ការឆ្លុះបញ្ចាំងរបស់សមាជិកក្រុមប្រឹក្សាឃុំ អញ្ជើញមកពីខេត្តស្វាយរៀង និងកំពង់ឆ្នាំង៖**

*«ឆ្នាំនេះពិតជាប្លែកជាមួយនឹងការតាំងបង្ហាញពីតម្រូវការតាមរយៈរោងការ ដែលបង្ហាញពីក្តីប្រាថ្នានៃការរៀបការរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាយើង។ យើងមានសុទិដ្ឋិនិយមថា តម្រូវការនេះនឹងមានការដឹងលឺដល់រាជរដ្ឋាភិបាល ហើយយើងបន្តធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន ដើម្បីលុបបំបាត់ការរើសអើងមកលើសហគមន៍។ ធ្វើអ្វីក៏ដោយ ត្រូវការពេល យើងបន្តព្យាយាមជាមួយគ្នាថែមទៀត ដូចសុភាសិតខ្មែរ តក់ៗពេញបំពង់ ។»*

ខ្ញុំទទួលយក

RoCK RAINBOW COMMUNITY KAMPUCHEA ORGANISATION

# សេចក្តីប្រកាសព័ត៌មាន






ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣៖ ក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងបណ្តាញអង្គការសង្គមស៊ីវិល បានរៀបចំកិច្ចសន្ទនាជាមួយតំណាងក្រសួង-ស្ថាប័នថ្នាក់ជាតិនិងអ្នកពាក់ព័ន្ធអំពីវឌ្ឍនភាពនៃជំហានបន្ទាប់ដើម្បីជំរុញការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។

(តំណភ្ជាប់នៃសេចក្តីប្រកាសព័ត៌មានជាភាសាខ្មែរ និងអង់គ្លេស)

https://www.facebook.com/100070867000927/posts/pfbid04pe4vWVAfTLdM9YdEvY6vrgtdxz3eq85HWQRi62yvdTkSvJAqykr6TDqP1QGZmbpl/?mibextid=cr9u03

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ការចុះផ្សាយព័ត៌មានពីកិច្ចសន្ទនា

១. អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា បន្តសន្ទនាជាមួយរដ្ឋាភិបាល ដើម្បីសមភាពច្បាប់អាពាហ៍ពិពាហ៍ (ថ្មីៗ , ថ្ងៃទី៧ ខែធ្នូ ឆ្នាំ ២០២៣) https://thmeythmey.com/m/?page=detail&id=132288...

២. អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា បន្តការស្នើសុំសមភាពច្បាប់អាពាហ៍ពិពាហ៍ (LGBT+ people in Cambodia continue to request for the legal marriage equality for same-sex couples, Phnom Penh Post, 05 December 2023 / ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣) LGBT community proposes marital equality discussions | Phnom Penh Post

៣. ខ្សែជីវិតរបស់ ផូ សុភា អ្នកប្ដូរអត្តសញ្ញាណយេនឌ័រពីបុរសមកស្ត្រីត្រូវបានឪពុកម្ដាយទទួលយកពេញលេញ (RFI Khmer, ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣) https://m.facebook.com/story.php?story_fbid=752809230205844&id=100064303224980&mibextid=ZbWKwL

៤. លោក កែវ រ៉េមី៖ អ្នកស្រឡាញ់ភេទដូចគ្នានៅតែទទួលបានការរើសអើងក្នុងសង្គម RFI Khmer, ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣) https://m.facebook.com/story.php?story_fbid=751976790289088&id=100064303224980&mibextid=ZbWKwL

៥. លោក កែវ រ៉េមី គាំទ្រដល់អ្នកស្រឡាញ់ភេទដូចគ្នា ដោយមិនទុកឱ្យឯកោ (ថ្មីៗ , ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣) https://fb.watch/oKzjzdFzDZ/?mibextid=NnVzG8...

៦. សគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាបន្តកិច្ចសន្ទនាជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីទទួលបានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា (CNC, ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣)
https://www.cnc.com.kh/detail/news/47672?fbclid=IwAR3OEHEsJ_RNERc4q6supUzdW5F2l1RMhT9_8tcvbkmGj6PbeZNT4hBSgHQ%E2%80%8B%20%E2%80%8B

៧. ឪពុកម្ដាយអ្នកស្រឡាញ់ភេទដូចគ្នា៖ បើកូនកើតមកបែបនេះហើយ គឺមានតែអាណិត (ថ្មីៗ , ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣) https://www.facebook.com/share/v/nWHpLS1yJzRXaYRu/?mibextid=Le6z7H&startTimeMs=2000

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

៨. ឪពុកម្តាយអ្នកស្រឡាញ់ភេទដូចគ្នា៖ បើកូនកើតមកបែបនេះហើយ គឺមានតែអាណិត
(ថ្មីៗ , ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣) https://www.facebook.com/ThmeyThmeyNews25/videos/1050424705994477/
៩. អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា បន្តសន្ទនាជាមួយរដ្ឋាភិបាល ដើម្បីសមភាពច្បាប់អាពាហ៍ពិពាហ៍ (ថ្មីៗ , ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣)
https://thmeythmey.com/?page=detail&id=132288&fbclid=IwAR0PW9v40Nez-qKYme_yVIFeHgrp2NAIuzjJ75SHd6-B8hCQt_bn3jJAzXc
១០. លោកធី  សុខុម ស្នើឱ្យរដ្ឋាភិបាលជួយដល់ចាស់ៗដែលស្រឡាញ់ភេទដូចគ្នា (ថ្មីៗ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣)
https://www.facebook.com/ThmeyThmeyNews25/videos/1512746856193638/
១១.សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាស្នើឱ្យបង្កើតក្រុមការងារចម្រុះ ដើម្បី ពិភាក្សាគ្នាលើការធ្វើច្បាប់អាពាហ៍ពិពាហ៍ (BST News Today
ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣) https://www.facebook.com/61553296070784/videos/3620547114854184/
១២. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ធ្វើពិធីអបអរសាទរទិវាសិទ្ធិមនុស្ស ១០ធ្នូ (BTVnews, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣)
https://www.btv.com.kh/article/36294?fbclid=IwAR3U3ruY9_bFFYku4NtuNCQCqWwAIjyfrEXsF99vUWqm6JnnAt3_9RIO2lc
https://www.facebook.com/watch/live/?extid=CL-UNK-UNK-UNK-AN_GK0T-GK1C&mibextid=2JQ9oc&ref=watch_permalink&v=347873027952542
១៣. PNN៖ បេសកកម្មប្រចាំសប្តាហ៍ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣)
(១) ពេងការសិប្បនិម្មិត តែងញ៉ាំងឲ្យអ្នកស្រលាញ់ភេទដូចគ្នារីករាយសប្បាយ
សូមទស្សនាវគ្គទី១៖ https://www.facebook.com/MissionOfTheWeek/videos/336564725837636
(២) អ្នកស្រលាញ់ភេទដូចគ្នាភាគច្រើនរៀបអាពាហ៍ពិពាហ៍ ក្រោមស្លាកថ្ងៃខួបកំណើត ឬឡើងគេហដ្ឋានថ្មី
សូមទស្សនាវគ្គទី២៖ https://www.facebook.com/watch/?v=1443844379886358
(៣) អ្នកស្រលាញ់ភេទដូចគ្នាកាន់តែច្រើន សម្រេចមិនរៀបការ ព្រោះរង់ចាំភាពស្របច្បាប់
សូមទស្សនាទី៣ (វគ្គបញ្ចប់)៖ https://www.facebook.com/watch/?v=7357819437595711

ខ្ញុំទទួលយក

សហគមន៍ឥន្ទធនូកម្ពុជា Rainbow Community Kampuchea-rock
Favorites · 5h

កូនមានមោទនភាព ដែលកើតមកជាកូនពុក ម៉ែ ដែលតែងតែគាំទ្រកូន និងផ្ដល់ភាពកក់ក្ដៅ ប្រកបដោយព្រហ្មវិហារធម៌។

https://www.facebook.com/share/v/nWHpLS1yJzRXaYRu/?mibextid=Le6z7H&startTimeMs=2000




ឪពុកម្ដាយអ្នកស្រឡាញ់ភេទដូចគ្នា៖ បើកូនកើតមកបែបនេះហើយ គឺមានតែអាណិត

https://m.facebook.com/story.php?sto... See more




RFI ខេមរភាសា / RFI Khmer posted a video to playlist ព័ត៌មានជាតិប្រចាំថ្ងៃ_៣.
5d

សហគមន៍ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា រួមនឹងបណ្ដាញសង្គមស៊ីវិលនិងក្រសួងស្ថាប័នពាក់ព័ន្ធនៅព្រឹកថ្ងៃទី៤ធ្នូនេះបានចូលរួមកិច្ចពិភាក្សាមួយដើម្បីបន្តជំរុញឱ្យមានការទទួលស្គាល... See more

សហគមន៍ឥន្ទធនូកម្ពុជា Rainbow Community Kampuchea-rock
Favorites · 2d

ការទទួលស្គាល់នូវបញ្ហាប្រឈម សេចក្តីត្រូវការអាទិភាពនៃកិច្ចការពារផ្នែកច្បាប់សម្រាប់គូស្រករ និងគ្រួសាររបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងកិច្ចសហការល្អ ដើម្បីស្វែងរកដំណោះស្រាយរួមគ្នារវាងរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធជាជំហានៗគឺជាលទ្ធផលវិជ្ជមាន។
#រ៉ក់ #rock #LGBTIQ #អ្នកស្រឡាញ់ភេទដូចគ្នា #ខ្ញុំទទួលយក #IAccept #IHRD2023 #កិច្ចសន្ទនា



PHNOMPENHPOST.COM
**LGBT community proposes marital equality discussions**
LGBT community proposes marital equality discussions

## សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា បន្តកិច្ចសន្ទនាជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ សម្រាប់គូស្រករភេទដូចគ្នា

០៤-ធ្នូ-២០២៣ ០៦:៤៧ ល្ងាច 332 Share



ខ្ញុំទទួលយក

# អ្នកចូលរួមកិច្ចសន្ទនាសរុបចំនួន២៣០នាក់

- សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាចំនួន១២៨នាក់ (៤២ដៃគូ) មកពី២០ខេត្ត និងរាជធានីភ្នំពេញ
- ឪពុកម្តាយ
- តំណាងរាជរដ្ឋាភិបាលនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងក្រសួងមហាផ្ទៃ
- អាជ្ញាធរមូលនៃក្រុមប្រឹក្សាឃុំ/សង្កាត់
- បណ្តាញអង្គការសង្គមស៊ីវិល
- តំណាងស្ថានទូតប្រចាំប្រទេសកម្ពុជា
- តំណាងអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
- សារព័ត៌មាន

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION




យើងទាំងអស់គ្នារស់នៅ និងជាម្ចាស់រួមគ្នាក្នុងសង្គមតែមួយដែលមានសមភាព សមធម៌ និងភាពសុខដុម!

# វីដេអូសង្ខេបកម្មវិធីកិច្ចសន្ទនា ក្នុងឱកាសអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣

https://www.facebook.com/RoCKHMERLGBT2009/videos/1026561155091620/?extid=CL-UNK-UNK-UNK-AN_GK0T-GK1C&mibextid=2JQ9oc




ខ្ញុំទទួលយក

RoCK RAINBOW COMMUNITY KAMPUCHEA ORGANISATION